# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ៤៥៦៤ ព.ណ.ក.ក.ប.ប

ថ្ងៃសុក្រ ៣កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០២៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចូលជាធរមាននៃអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច

គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា «គ.ប.ក.» ដែលមានអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «ក.ប.ប.» នៃក្រសួងពាណិជ្ជកម្ម ជាសេនាធិការនិងលេខាធិការដ្ឋាន មានកិត្តិយសសូមជម្រាបជូនដល់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី និងធុរជនទាំងអស់ មេត្តាជ្រាបថា អនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច ដែលត្រូវបានរាជរដ្ឋាភិបាលអនុម័តកាលពីថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ នឹងត្រូវចូលជាធរមាននៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ខាងមុខនេះ។ អនុក្រឹត្យនេះមានគោលបំណងត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើផលប៉ះពាល់ចំពោះការប្រកួតប្រជែង ដែលអាចកើតមានឡើងតាមរយៈការរួមបញ្ចូលគ្នានៃធុរកិច្ច ព្រមទាំងរារាំងរាល់ការរួមបញ្ចូលគ្នានៃធុរកិច្ចទាំងឡាយណាដែលមិនអនុលោមនិងអាចបំពានបទប្បញ្ញត្តិជាធរមាន។

តាមរយៈអនុក្រឹត្យនេះ កាតព្វកិច្ចសំខាន់ៗពាក់ព័ន្ធនឹងការរួមបញ្ចូលគ្នានៃធុរកិច្ច ចំនួន ០៣ រួមមាន៖ (១).ការជូនដំណឹងជាមុនអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច (២).ការជូនដំណឹងជាក្រោយអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច និង(៣).ការចុះបញ្ជីការរួមបញ្ចូលគ្នានៃធុរកិច្ច។ លក្ខខណ្ឌនិងនីតិវិធីនៃការជូនដំណឹងនិងការចុះបញ្ជីការរួមបញ្ចូលគ្នានៃធុរកិច្ច ត្រូវអនុលោមតាមសេចក្តីសម្រេចស្តីពីកម្រិតកំណត់នៃការជូនដំណឹងជាមុនអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច ប្រកាសស្តីពីនីតិវិធីនៃការជូនដំណឹងជាក្រោយនៃការរួមបញ្ចូលគ្នានៃធុរកិច្ច និងប្រកាសស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីការរួមបញ្ចូលគ្នានៃធុរកិច្ចដែលត្រូវជូនដំណឹងជាមុន។

ប្រសិនបើ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី និងធុរជនទាំងអស់ មានចម្ងល់ពាក់ព័ន្ធនឹងអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធ អាចធ្វើការទំនាក់ទំនងមកអគ្គនាយកដ្ឋាន ក.ប.ប. តាមរយៈអាសយដ្ឋានផ្លូវលេខ១៨ ភូមិក្តីតាកុយ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ Email: info@ccfdg.gov.kh Phone: (+855) 23 231 856 (+855) 92 830 856 ឬតាមគេហទំព័រ https://www.ccfdg.gov.kh/ ឬតាមហ្វេសប៊ុក https://www.facebook.com/ccfkh/។

សូមទាញយកឯកសារពាក់ព័ន្ធតាមរយៈQR Code៖

សូមអរគុណ!